ភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៣

# សេចក្ដីសម្រេចលេខ ០២ សសរ ស្ដីពីការកំណត់ ថវិកាសម្រាប់កែលំអព្រលានយន្តហោះពោធិចិនតុង

***

## រដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា

យោងព្រះរាជក្រឹត្យរបស់សម្ដេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣

យោងអនុក្រឹត្យលេខ ០២ អនក្រ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៣

## សម្រេច

**ប្រការ ១** : នាយកដ្ឋានអាកាសចរស៊ីវិលកម្ពុជា ត្រូវដកប្រាក់ចំនួន ២០ ភាគរយ នៃប្រាក់ចំណូលសរុបដែលបាន មកពីពន្ធចុះចតពន្ធព្រលានយន្តហោះ និង ចំណូលផ្សេងៗ ទៀតសម្រាប់ធ្វើការកែលំអ និង រៀបចំឡើង វិញ ព្រលានយន្តហោះពោធិចិនតុង។

**ប្រការ ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ។

**សហប្រធាន**

រដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា

ព្រះហស្តលេខា　　　　ហត្ថលេខា

ស្ដេចក្រុមហ្លួង នរោត្តម រណឫទ្ធិ　　　　ហ៊ុន សែន

****